# របាយការណ៍ក្រសួងការបរទេសសហរដ្ឋអាមេរិក

# របាយការណ៍ស្តីពីការជួញដូរមនុស្សឆ្នាំ២០១៤

# ប្រទេសកម្ពុជា - (លំដាប់ថ្នាក់ទី ២ ក្នុងបញ្ជីតាមដាន)

កម្ពុជាគឺជាប្រទេសប្រភព និងជាប្រទេសឆ្លងកាត់ និងជាប្រទេសគោលដៅសំរាប់បុរស ស្ត្រី និង កុមារ ដែលរងគ្រោះដោយការចាប់បង្ខំអោយធ្វើពលកម្ម និងការជួញដូរផ្លូវភេទ ។ ប្រជាជនកម្ពុជាពេញវ័យនិង កុមារកម្ពុជាធ្វើចំណាកស្រុកទៅប្រទេសដទៃទៀតនៅក្នុងតំបន់ ហើយក្នុងចំនួនកាន់តែច្រើនឡើង ទៅទ្វីបអាហ្វ្រិក ដើម្បីរកការងារធ្វើ។ ពួកគេជាច្រើននាក់បានធ្លាក់ទៅក្នុងការជួញដូរផ្លូវភេទ ការបង្ខំអោយបំរើនៅក្នុងផ្ទះដូចជាទាសករ ធ្លាក់ទៅក្នុងទាសភាពបំណុលឬត្រូវបានគេបង្ខំអោយធ្វើពលកម្មធ្ងន់ធ្ងក្នុងទូកនេសាទ ក្នុងវិស័យកសិកម្ម ឬនៅតាមរោងចក្រ។ កម្មករចំណាកស្រុកកម្ពុជា ពិសេសនៅប្រទេសថៃ និងម៉ាឡេស៊ី ងាយនឹងរងការបង្ខំអោយធ្វើពលកម្ម និងទាសភាពបំណុល។ ថៅកែនៅក្នុងប្រទេសដែលគេទៅនោះមិនព្រមផ្តល់សំណៅនៃកិច្ចសន្យាការងារ ហើយដកយកលិខិតឆ្លងដែនទុក។ ទីភ្នាក់ងារជ្រើសរើសពលករបានក្លែងឯកសារសំគាល់ខ្លួនស្របច្បាប់ និងឯកសារបញ្ជាក់ពីអាយុ ដើម្បីសំរួលដល់ការជ្រើសរើសកុមារដោយខុសច្បាប់។ ទោះបីជាមានការហាមប្រាមជាបន្តក្តី តែស្ត្រី និង កុមារកម្ពុជានៅតែបន្តធ្វើចំណាកស្រុកទៅប្រទេសម៉ាឡេស៊ី ដើម្បីធ្វើការងារបំរើតាមផ្ទះ។ ស្ត្រីទាំងនេះច្រើនធ្វើដំណើរដោយប្រើទិដ្ឋាការទេសចរ ហើយឆ្លងកាត់ប្រទេសថៃ។ មានខ្លះក្លាយជាជនរងគ្រោះដោយការបង្ខំអោយបំរើការនៅក្នុងផ្ទះ។ បុរសខ្មែរនៅតែទទួលរងការបង្ខំអោយធ្វើការនៅលើទូកនេសាទដែលដោតទង់ជាតិថៃ នៅលើសមុទ្រអន្តរជាតិ។គេមិនដឹងចំនួនជនជាតិខ្មែរដែលរងការកេងប្រវ័ញ្ចបែបនេះទេ តែអ្នកសង្កេតការណ៍ក្នុងស្រុកបានសំដែងកង្វល់លើនិន្នាការដែលមានកាន់តែច្រើននៃជនរងគ្រោះ ដែលត្រូវបានគេជួញដូរនៅក្នុងឧស្សាហកម្មនេសាទ។ ជនរងគ្រោះខ្មែរដែលគេចចេញពីជនប្រព្រឹត្តការជួញដូរក្នុងឧស្សាហកម្មនេសាទត្រូវបានគេដឹងថា មកពីប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី Mauritius ហ្វីជី សេណេហ្គាល់ និងអាហ្វ្រិកខាងត្បូង។ បុរសខ្មែរបាននិយាយពីការត្រូវបានគេបោកអំពីរយៈពេលការងារ និងប្រាក់ឈ្នួលដែលផ្តល់ដោយថៅកែទូកនេសាទនៅប្រទេសថៃ ដែលនៅទីនោះ ភាគច្រើនត្រូវបានគេជ្រើសរើសអោយធ្វើការក្នុងផ្នែកនេសាទ។ អ្នកខ្លះបាននិយាយពីការធ្វើបាបយ៉ាងខ្លាំងដោយអ្នកគ្រប់គ្រងទូក ហើយនិងការបង្ខំអោយនៅលើទូករាប់ឆ្នាំ។

កុមារនៅក្នុងគ្រួសារក្រីក្រងាយរងគ្រោះខ្លាំងដោយការបង្ខំអោយធ្វើពលកម្ម ដែលរួមមានការបង្ខំអោយធ្វើជាឈ្នួលបំរើតាមផ្ទះ និងត្រូវបានបង្ខំអោយដើរសុំទាន នៅប្រទេសថៃ និងប្រទេសវៀតណាម។ ជាញឹកញាប់ឪពុកម្តាយច្រើនមានការពាក់ព័ន្ធក្នុងទង្វើបែបនេះ ។ តំបន់ស្វាយប៉ាកនៅក្រៅក្រុងភ្នំពេញ ដែលនៅទីនោះ ក្មេងស្រីជាច្រើនរងការកេងប្រវ័ញ្ចក្នុងជំនួញផ្លូវភេទ មាននាទីជាកន្លែងឆ្លងកាត់បណ្តោះអាសន្នសំរាប់កុមាររងគ្រោះដោយការជួញដូរផ្លូវភេទ ពីប្រទេសវៀតណាម ដែលនៅពេលបន្ទាប់មក ត្រូវបានគេកេងប្រវ័ញ្ចនៅតាមសណ្ឋាគារ និងកន្លែងដទៃទៀត នៅភ្នំពេញ។  នៅប្រទេសកម្ពុជា ស្ត្រីនិងកុមារវៀតណាម និងកម្ពុជាមកពីតំបន់ជនបទមកក្រុងភ្នំពេញ សៀមរាប ប៉ោយប៉ែត កោះកុង និងទីក្រុងព្រះសីហនុ  ហើយនៅតំបន់ទាំងនេះ ពួកគេរងការជួញដូរផ្លូវភេទ នៅតាមផ្ទះបន ហើយកាន់តែច្រើន នៅតាមកន្លែងកំសាន្ត ដូចជាបៀហ្គាដិន ហាងម៉ាស្សាហាងខារាអូខេ និងកន្លែងមិនធ្វើពាណិជ្ជកម្មនានា។ ការជួញដូរផ្លូវភេទលើកុមារអាយុក្រោម ១៥ ឆ្នាំ ដែលពីមុនត្រូវបានគេផ្សាយតាមវិធីដែលមានលក្ខណៈចំហ តែបច្ចុប្បន្ន កាន់តែមានការលួចលាក់ច្រើនឡើង។ ការលក់កុមារ និងនារីព្រហ្មចារីនៅតែចោទជាបញ្ហានៅកម្ពុជា។ បុរសកម្ពុជាគឺជាប្រភពតំរូវការធំជាងគេលើពេស្យាចារកុមារ។ តែបុរសមកពីប្រទេសដទៃនៅអាស៊ី សហរដ្ឋអាមេរិក និងអឺរ៉ុប ធ្វើដំណើរមកកម្ពុជា ដើម្បីធ្វើទេសចរណ៍ផ្លូវភេទលើកុមារ។

ស្ត្រីនិងកុមារវៀតណាម ដែលមានច្រើនជាជនរងគ្រោះដោយទាសភាពបំណុល ធ្វើដំណើរមកកម្ពុជា ហើយត្រូវបានបង្ខំអោយបំរើផ្លូវភេទជាលក្ខណៈពាណិជ្ជកម្ម។ អង្គការមិនមែនរដ្ឋាភិបាលរាយការណ៍ថា ជនរងគ្រោះជាជនជាតិវៀតណាមត្រូវបានដឹកឆ្លងកាត់ប្រទេសកម្ពុជាដោយក្រុមឧក្រិដ្ឋជន មុនពេលត្រូវបានកេងប្រវ័ញ្ចនៅប្រទេសថៃ និងម៉ាឡេស៊ី។ មន្ត្រីពុករលួយនៅកម្ពុជា ថៃ និងម៉ាឡេស៊ីរួមគ្នាជាមួយឈ្មួញកណ្តាលដែលជ្រើសរើសពលករ ដើម្បីសំរួលដល់ការដឹកជញ្ជូនជនរងគ្រោះឆ្លងកាត់ព្រំដែន។ លើសពីនេះទៀត ជនរងគ្រោះដោយការជួញដូរដែលគេមិនស្គាល់ និងក្នុងចំនួនដែលគេមិនដឹង ស្ថិតនៅក្នុងចំណោមជនចំណាកស្រុកដ៏ច្រើន ដែលត្រូវចាប់បញ្ជូនមកពីប្រទេសថៃ ក្នុងមួយឆ្នាំៗ។

រដ្ឋាភិបាលកម្ពុជាមិនបានគោរពបានពេញលេញតាមបទដ្ឋានអប្បបរិមាសំរាប់ការបំបាត់ការជួញដូរមនុស្សទេ ។ ទោះជាយ៉ាងណាក្តី ក៏រដ្ឋាភិបាលកំពុងតែខិតខំច្រើនគួរសមក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ។ រដ្ឋាភិបាលបានតាក់តែងពង្រាងគោលការណ៍ណែនាំសំរាប់ធ្វើអោយមានប្រព័ន្ធជាបទដ្ឋាន ទូទាំងប្រទេសសំរាប់កំណត់ជនរងគ្រោះក្នុងចំណោមក្រុមមនុស្សដែលងាយរងគ្រោះជាងគេ ហើយបានអនុវត្តកម្មវិធីសាកល្បងមួយ ដើម្បីស្ទង់ប្រសិទ្ធភាពនៃគោលការណ៍ណែនាំទាំងនេះ នៅក្នុងខេត្តចំនួនពីរ។ទោះបីជាមានវិធានការទាំងនេះក្តី ក៏រដ្ឋាភិបាលមិនបានបង្ហាញអោយឃើញភស្តុតាងនៃការបង្កើនការខិតខំជារួមក្នុងការដោះស្រាយបញ្ហាជួញដូរមនុស្សអោយបានច្រើនលើសឆ្នាំកន្លងទៅទេដែរ។ ដូច្នេះ ប្រទេសកម្ពុជាត្រូវបានដាក់អោយស្ថិតនៅក្នុង

ចំណាត់ថ្នាក់លេខ ២ ក្នុងបញ្ជីតាមដាន។ កម្ពុជាមិនសំរេចបានភាពជឿនលឿនទៅមុខទេ ក្នុងការចាប់ជនប្រព្រឹត្ត ការជួញដូរមនុស្ស អោយទទួលខុសត្រូវ។ ថ្វីបើទំរង់ជាច្រើននៃការជួញដូរមនុស្សបានបន្តកើតមាននៅកម្ពុជាក្តី តែ រដ្ឋាភិបាលបានកាត់ទោស និងដាក់ទោសជនប្រព្រឹត្តការជួញដូរ ហើយបានកំណត់បានជនរងគ្រោះតិចជាងកាល ពីឆ្នាំកន្លងទៅ។ ការដែលតុលាការកំពូលបានលើកលែងការចោទប្រកាន់ទៅលើអតីតមេនគរបាលដែលត្រូវបាន ដាក់ទោសក្នុងឆ្នាំ ២០១១ ពីបទជួញដូរ រួមនឹងការខកខានជាទូទៅក្នុងការដោះស្រាយបញ្ហាសមគំនិតទាក់ទង នឹងការជួញដូរ បានជួយបង្កើតអោយមានបរិយាសកាសនិទណ្ឌភាពសំរាប់ជនប្រព្រឹត្តការជួញដូរ ហើយនិងការធ្វើ អោយជនរងគ្រោះមិនអាចទទួលបានយុត្តិធម៌។ ទោះបីជាមានការយកចិត្តទុកដាក់ច្រើនឡើងពីរដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាលទៅលើការមានច្រើនឡើងនៃជនរងគ្រោះជាបុរសក្តី តែសេវាសំរាប់ក្រុមជនរងគ្រោះនេះ នៅតែមានកំរិតនៅឡើយ។ រដ្ឋាភិបាលត្រូវបានរាយការណ៍មកថា បានដាក់អនុព័ន្ធការងារនៅតាមស្ថានទូតចំនួនបី របស់ខ្លួន នៅក្នុងប្រទេសដែលមានកម្មករខ្មែរច្រើន ហើយផ្តល់ការបង្រៀនជាទូទៅពីការប្រឆាំងនឹងការជួញដូរ មនុស្សដល់អ្នកការទូតទាំងអស់របស់ខ្លួន មុនពេលបញ្ជូនពួកគេអោយទៅធ្វើការនៅបរទេស តែគេខ្វះនិតិវិធីជា ប្រព័ន្ធសំរាប់អោយបេសកកម្មទូតរបស់ខ្លួននៅបរទេសជួយជនរងគ្រោះបាន។ រដ្ឋាភិបាលមិនបានផ្តល់អោយច្បាស់ លាស់ដល់នគរបាលនូវអំណាចក្នុងការធ្វើប្រតិបត្តិការសំងាត់ប្រឆាំងនឹងការជួញដូរមនុស្សទេ ថ្វីបើក្រសួងយុត្តិធម៌ លើកទឹកចិត្តអោយមន្ត្រីប្រើប្រាស់និតិវិធីសំរាប់សុំការអនុញ្ញាតអោយធ្វើការស៊ើបអង្កេតដោយសំងាត់ ដែលត្រូវបាន អនុញ្ញាតនៅក្នុងរង្វង់ក្របខ័ណ្ឌច្បាប់បច្ចុប្បន្ន នៅក្នុងសិក្ខាសាលាដែលឧបត្ថម្ភដោយម្ចាស់ជំនួយ កាលពីខែធ្នូ។

**អនុសាសន៍សំរាប់ប្រទេសកម្ពុជា៖** បង្កើនការខិតខំក្នុងការស៊ើបអង្កេត និងនាំខ្លួនយកមកកាត់ទោស ដាក់ទោស និងដាក់ទណ្ឌកម្មចំពោះជនល្មើសក្នុងការជួញដូរ ទាំងអ្នកជួញដូរពលករ ទាំងអ្នកជួញដូរផ្លូវភេទ ចេញប្រកាស ឬការណែនាំផ្លូវការដទៃទៀតដែលអនុញ្ញាតអោយមានការប្រើបច្ចេកទេសស៊ើបអង្កេតសំងាត់ នៅក្នុងការអនុវត្ត ច្បាប់ប្រឆាំងការជួញដូរ ខិតខំចាប់អោយមន្ត្រីទទួលខុសត្រូវចំពោះការរួមគំនិតក្នុងការជួញដូរមនុស្ស ធ្វើអោយផ្នែក សមត្ថកិច្ច និងអ្នករៀបចំគោលនយោបាយទាញការយកចិត្តទុកដាក់ទៅលើការកើនច្រើនឡើងនៃការជួញដូរបុរស ពិសេសនៅក្នុងទូកនេសាទក្រុមហ៊ុន ហើយបង្កើតសេវាថែមសំរាប់ជួយដល់ជនរងគ្រោះបុរស សំរួលនិតិវិធីសំរាប់ ធ្វើការរាយការណ៍ និងឆ្លើយតបទៅនឹងករណីដែលជនរងគ្រោះត្រូវបានរកឃើញនៅតាមប្រទេសដែលកម្ពុជាគ្មាន តំណាងទូតនៅក្នុងនោះ  បង្កើតអោយមាននិតិវិធីជាប្រព័ន្ធដើម្បីជួយជនរងគ្រោះខ្មែរ តាមរយៈបេសកកម្មការទូត នៅបរទេស ប្រហែលដោយតែងតាំងអនុព័ន្ធម្នាក់ដែលធ្វើតែការងារនេះក្នុងប្រទេសដែលមានចំនួនកម្មករខ្មែរច្រើន ផ្តល់ការបង្រៀនពីការងារប្រឆាំងនឹងការជួញដូរមនុស្សដល់អ្នកការទូតទាំងអស់របស់ខ្លួន មុនពេលបញ្ជូនពួកគេ

អោយទៅធ្វើការនៅបរទេស សំរេច និងអនុវត្តពិធីសារនៅទូទាំងប្រទេសក្នុងការកំណត់អត្តសញ្ញាណនៃជនរងគ្រោះក្នុងចំណោមជនដែលងាយរងគ្រោះ ដាក់ទោសព្រហ្មទណ្ឌចំពោះក្រុមហ៊ុនជ្រើសរើសពលករ ដែលល្មើសច្បាប់ដែលនាំអោយមានការឈានដល់ការជួញដូរមនុស្ស ធ្វើបច្ចុប្បន្នភាពលើផែនការសកម្មភាពថ្នាក់ជាតិរបស់គណកម្មាធិការជាតិ ដើម្បីប្រឆាំងការជួញដូរ បន្ថែមការងាររបស់រដ្ឋាភិបាលក្នុងការបញ្ជូនជនរងគ្រោះដោយការជួញដូរទៅអោយអង្គការមិនមែនរដ្ឋាភិបាល ជាមួយនឹងការបង្កើនការឧបត្ថម្ភគាំទ្រ និងសេវាកម្ម ដែលរួមមានជំនួយផ្លូវច្បាប់ ការជួយផ្នែកចិត្តវិទ្យា និងសង្គម កម្មវិធីសមាហរណកម្ម កែលំអកិច្ចសហការ និងសហប្រតិបត្តិការជាអន្តរទីភ្នាក់ងាររវាងនគរបាល មន្ត្រីតុលាការ និងបុគ្គលិកដទៃទៀតរបស់រដ្ឋ លើករណីជួញដូរ និងដំណើរការនៃការបញ្ជូនជនរងគ្រោះធានាថា អនុស្សារណៈនៃការយោគយល់គ្នាស្តីពីការបញ្ជូនពលករកម្ពុជាទៅបរទេសត្រូវមានចែងពីបញ្ញត្តិការពាររឹងមាំ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់ពលករដោយសារការជួញដូរ បង្កើនការខិតខំធ្វើអោយដំណើរតុលាការមានប្រសិទ្ធភាពច្រើន និងគិតគូរពីសេចក្តីត្រូវការនិងផលប្រយោជន៍របស់ជនរងគ្រោះដោយការជួញដូរ ដោយរួមមានទាំងតាមរយៈការផ្តល់ការការពារពីសាក្សី ហើយពង្រីកនិងបន្តប្រកាសយុទ្ធនាការលើកកំពស់ការយល់ដឹងដើម្បីកាត់បន្ថយតំរូវការលើទេសចរណ៍ផ្លូវភេទលើកុមារ និងការជួញដូរផ្លូវភេទ ដោយផ្តោតអោយបានច្រើនលើការដោះស្រាយបញ្ហាតំរូវការក្នុងស្រុកលើការលក់ដូរផ្លូវភេទលើកុមារ។

## ការនាំខ្លួនយកមកកាត់ទោស

ការខិតខំរបស់រដ្ឋាភិបាលកម្ពុជាក្នុងការចាប់អោយជនប្រព្រឹត្តការជួញដូរទទួលខុសត្រូវមានការធ្លាក់ចុះយ៉ាងច្រើន។ ច្បាប់ដែលត្រូវបានដាក់ចេញនៅឆ្នាំ ២០០៨ ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការធ្វើអាជីវកម្មកេងប្រវ័ញ្ចផ្លូវភេទមាននិយាយច្បាស់ពីបទល្មើសជួញដូរជាច្រើន ក្នុងមាត្រាចំនួន ១២ ក្នុងចំណោមមាត្រាចំនួន ៣០ ក្នុងច្បាប់នេះ។ ច្បាប់នៅកម្ពុជាហាមប្រាមគ្រប់ទំរង់ទាំងអស់នៃការជួញដូរមនុស្ស ចែងពីការដាក់ទោសចំពោះបទល្មើស ដែលមានភាពម៉ឺងម៉ាត់គ្រប់គ្រាន់ និងស្របតាមទោសសំរាប់បទឧក្រិដ្ឋធ្ងន់ធ្ងរដទៃទៀត ដូចជាការរំលោភសេពសន្ថវៈ។ ក្នុងឆ្នាំនៃរបាយការណ៍នេះ រដ្ឋាភិបាលបាននិយាយថា បាននាំមកកាត់ទោសចំនួន ៣៥ ករណីនៃការជួញដូរ បានផ្តន្ទាទោសលើជនប្រព្រឹត្តការជួញដូរផ្លូវភេទ ១០ នាក់ និងជនប្រព្រឹត្តការជួញដូរពលកម្ម ៨ នាក់ ។ ចំនួននេះថយចុះពីឆ្នាំមុនដែលមានការផ្តន្ទាទោសចំនួន ៤៤ នាក់។ ករណីមួយក្នុងចំណោមករណីផ្តន្ទាទោសទាំង ៣៥ នេះ មានការពាក់ព័ន្ធនឹងការជួញដូរកំលាំងពលកម្មក្នុងផ្នែកនេសាទ ។ នៅខែឧសភា ឆ្នាំ ២០១៣ អាជ្ញាធរខ្មែរបានចាប់ខ្លួនជនជាតិតៃវ៉ាន់ម្នាក់ពីបទចោទថា បានជួញដូរបុរសខ្មែររាប់រយនាក់នៅលើទូកនេសាទថៃ នៅក្នុងសមុទ្រអន្តរជាតិ។ នៅពេលបញ្ចប់នៃពេលកំណត់នៃរបាយការណ៍ ជនសង្ស័យស្ថិតនៅក្នុងការឃុំខ្លួនមិនទាន់មាន

សវនាការនៅឡើយ។ រដ្ឋាភិបាលកម្ពុជាបានបន្តរៀបចំនិងបើកការបណ្តុះបណ្តាលក្រោមជំនួយរបស់ម្ចាស់អំណោយ ស្តីពីការអនុវត្តច្បាប់ប្រឆាំងនឹងការជួញដូរ សំរាប់មន្ត្រីតុលាការ និងសមត្ថកិច្ចចំនួន ១២០០ រូប តែមន្ត្រីខ្វះជំនាញ ក្នុងការកំណត់ និងកាត់ទោសករណីជួញដូរយ៉ាងច្រើន។ ពេលខ្លះ មន្ត្រីទាំងនោះបញ្ចូលជាមួយគ្នានូវការជួញដូរ ពលកម្មនិងការជួញដូរមនុស្ស ហើយកង្វះជំនាញក្នុងការប្រមូលភស្តុតាងនាំអោយមន្ត្រីទាំងនោះពឹងផ្អែកស្ទើរតែ ទាំងស្រុងលើកសិណសាក្សីរបស់ជនរងគ្រោះសំរាប់កសាងសំណុំរឿង។ ការខិតខំមិនគ្រប់គ្រាន់ដើម្បីការពារជនរង គ្រោះ ដោយរួមទាំងកង្វះការលើកទឹកចិត្តអោយជនរងគ្រោះចូលរួមក្នុងការកាត់ទោស បានធ្វើអោយពួកគេជាច្រើន មិនចង់ចូលរួម។ ជនរងគ្រោះដែលគ្រួសាររបស់គេបានទទួលសំណងនៅក្រៅតុលាការពីជនប្រព្រឹត្តការជួញដូរ ពេលខ្លះផ្លាស់ប្តូរចំលើយជាកសិណរបស់គេ ដែលជាឧបសគ្គមួយធ្វើមិនអោយដំណើរការកាត់ទោសទទួលបាន ជោគជ័យ។ ថ្វីបើរដ្ឋាភិបាលនៅរក្សាកិច្ចព្រមព្រៀងដែលអំពាវនាវអោយមានការស៊ើបអង្កេតរួមគ្នាទៅលើករណី ជួញដូរជាមួយរដ្ឋាភិបាលនៃប្រទេសថៃ និងវៀតណាមក្តី តែគ្មានសេចក្តីរាយការណ៍ពីសហប្រតិបត្តិការអន្តរជាតិ ជាមួយនឹងរដ្ឋាភិបាលទាំងនេះទេ នៅក្នុងឆ្នាំធ្វើរបាយការណ៍នេះ។ អង្គការក្នុងស្រុកនិងមន្ត្រីខ្លះមើលឃើញពីតំរូវការ បន្ទាន់នៃការមានបច្ចេកទេសប្រមូលភស្តុតាងល្អថ្មីៗថែមទៀត ដោយរួមមានទាំងការស៊ើបអង្កេតសំងាត់ ដើម្បី បន្ថយការពឹងផ្អែកលើចំលើយជាកសិណរបស់សាក្សី និងសំរបតាមលក្ខណៈផ្លាស់ប្តូរនៃការជួញដូរផ្លូវភេទ ដែល កាន់តែមានភាពបិទបាំងច្រើន ហើយពិបាកបង្ហាញនៅក្នុងតុលាការ នៅកម្ពុជា។ ថ្វីបើការប្រមូលភស្តុតាងដោយ សំងាត់ក្នុងករណីជួញដូរមនុស្សមិនត្រូវបានហាមប្រាមច្បាស់ដោយច្បាប់នៅកម្ពុជាក្តី តែក្នុងពេលប៉ុន្មានឆ្នាំថ្មីៗនេះ ចៅក្រមកម្ពុជាបានចាត់ទុកការធ្វើបែបនេះថាខុសច្បាប់។ ថ្វីបើរដ្ឋាភិបាលបានយល់ព្រមច្បាស់លាស់លើអំណាចធ្វើ ការស៊ើបអង្កេតដោយសំងាត់ ចំពោះបទល្មើសប្រភេទផ្សេងទៀតក្តី ដូចជាការប្រឆាំងនឹងគ្រឿងញៀន  តែការយល់ ព្រមដូចគ្នានេះមិនត្រូវបានផ្តល់អោយបានច្បាស់លាស់ដល់ការស៊ើបអង្កេតលើបទល្មើសដែលជាប់សង្ស័យ នៅ ក្រោមច្បាប់ ប្រឆាំងការជួញដូរមនុស្ស ឆ្នាំ ២០០៨ ឡើយ។

អំពើពុករលួយដែលមានជាទូទៅនៅគ្រប់លំដាប់ថ្នាក់ទាំងអស់ក្នុងរដ្ឋាភិបាលកម្ពុជារឹតត្បិតយ៉ាងខ្លាំង ដល់សមត្ថភាពរបស់មន្ត្រីម្នាក់ៗក្នុងការចាប់អោយជនប្រព្រឹត្តការជួញដូរទទួលខុសត្រូវ។ អ្នកសង្កេតការក្នុងស្រុក និយាយថា មន្ត្រីពុករលួយតែងធ្វើអោយរាំងស្ទះដល់ដំណើរជឿនលឿន ក្នុងករណីដែលមានការទាក់ទងផ្នែកនយោ បាយ ព្រហ្មទណ្ឌ ឬសេដ្ឋកិច្ចជាមួយមន្ត្រីរដ្ឋាភិបាល ហើយរដ្ឋាភិបាលខកខានមិនបានចាប់អោយមន្ត្រីទទួលខុស ត្រូវចំពោះទង្វើបែបនេះទេ។  រដ្ឋាភិបាលមិនបានរាយការណ៍ពីការស៊ើបអង្កេត ការកាត់ទោស ឬការដាក់ទោសលើ បុគ្គលិករដ្ឋដែលមានការសមគំនិតក្នុងការជួញដូរមនុស្សទេ។ នៅខែវិច្ឆិកា ឆ្នាំ ២០១៣ តុលាការកំពូលបានបើក

សវនាការបិទទ្វារ ដោយមិនប្រកាស ហើយបានលុបចោលការចោទប្រកាន់ទាំងអស់លើអតីតប្រធានការិយាល័យនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន រាជធានីភ្នំពេញ ដែលត្រូវបានដាក់ទោសដោយកំបាំងមុខពីបទជួញដូរមនុស្ស និងបទល្មើសទាក់ទងនឹងបទល្មើសនេះ កាលពីឆ្នាំ ២០១១។

**ការការពារ** ( Protection )

រដ្ឋាភិបាលបានបន្តប្រើនិតិវិធីសំរាប់កំណត់ជនរងគ្រោះ ហើយបញ្ជូនគេទៅអោយអង្គការមិនមែនរដ្ឋាភិបាល តែចំនួនជនរងគ្រោះដែលត្រូវបានរកឃើញមានការថយចុះ បើប្រៀបធៀបនឹងរយៈពេលនៃរបាយការណ៍មុន។ ក្រសួងសង្គមកិច្ចបានរាយការណ៍ពីការបានទទួល និងបានបញ្ជូនជនរងគ្រោះដោយការជួញដូរចំនួន ៣១០ នាក់ទីកាន់កន្លែងផ្តល់ទីជំរក របស់អង្គការមិនមែនរដ្ឋាភិបាល។ ចំនួននេះមានការថយចុះពីចំនួន ៥៧០ នាក់ដែលត្រូវបានបញ្ជូននៅក្នុងអំឡុងពេលនៃរបាយការណ៍លើកមុន។ នគរបាលមូលដ្ឋានបានបញ្ជូនជនរងគ្រោះដោយការជួញដូរផ្លូវភេទចំនួន ១៥១ នាក់ទៅស្ថាប័នខេត្តសំរាប់ការបញ្ជូនបន្តទៅអង្គការមិនមែនរដ្ឋាភិបាល។ ចំនួននេះមានការថយចុះពីចំនួន ៣៨៨ នាក់ ដែលត្រូវបានបញ្ជូន នៅក្នុងអំឡុងពេលនៃរបាយការណ៍ឆ្នាំមុន។ រដ្ឋាភិបាលបានតាក់តែងពង្រាងគោលការណ៍ណែនាំសំរាប់ធ្វើអោយមានប្រព័ន្ធជាបទដ្ឋាន ទូទាំងប្រទេសសំរាប់កំណត់ជនរងគ្រោះក្នុងចំណោមក្រុមមនុស្សដែលងាយរងគ្រោះជាងគេ តែបានតាក់តែងពង្រាងគោលការណ៍ និងអនុវត្តកម្មវិធីសាកល្បងមួយ ដើម្បីស្ទង់ប្រសិទ្ធភាពនៃគោលការណ៍ណែនាំទាំងនេះ នៅក្នុងខេត្តចំនួនពីរ។ រដ្ឋាភិបាលបានដំណើរការកន្លែងជំរកបណ្តោះអាសន្នមួយនៅភ្នំពេញសំរាប់ទទួលជនរងគ្រោះដោយការជួញដូរ និងបទល្មើសផ្សេងទៀតជាស្ត្រី និងកុមារី តែរដ្ឋាភិបាលមិនបានផ្តល់ជំនួយអ្វីថែមទៀតដល់ជនរងគ្រោះឡើយ។ ដោយមានជំនួយពីអង្គការអន្តរជាតិមួយ ក្រសួងសង្គមកិច្ចបានបន្តដំណើរការមជ្ឈមណ្ឌលទទួលអោយស្នាក់នៅបណ្តោះអាសន្នមួយនៅប៉ោយប៉ែត ដែលនៅទីនោះ ក្រសួងបានទទួលជនរងគ្រោះចំនួន ១៥៩ នាក់ដែលរកឃើញដោយអាជ្ញាធរថៃ។ និតិវិធីនៃការកំណត់ជនរងគ្រោះនៅសងខាងព្រំដែនគឺមានភាពមិនគ្រប់គ្រាន់ទេ ហើយចំនួនជនរងគ្រោះជាក់ស្តែង នៅក្នុងចំណោមប្រជាជនកម្ពុជាចំនួន ៥៥ ០០០ នាក់ ដែលត្រូវចាប់បញ្ជូនមកពីប្រទេសថៃវិញ ទំនងជាមានច្រើនជាងនេះឆ្ងាយ។ រដ្ឋាភិបាលបានបញ្ជូនជនរងគ្រោះចំនួន ១៧០ នាក់ ដែលត្រូវបញ្ជូនមកពីប្រទេសវៀតណាមវិញ ដោយមានជំនួយពីអង្គការអន្តរជាតិមួយ។ អង្គការមិនមែនរដ្ឋាភិបាលខ្មែរនិងបរទេសបានធ្វើមាតុភូមិនិវត្តន៍ក្រៅផ្លូវការនូវជនរងគ្រោះនៅលើទូកនេសាទថៃ ក្នុងចំនួនដែលគេមិនបានដឹង។ អង្គការមួយបានរាយការណ៍ថា បាននាំត្រឡប់វិញនូវជនរងគ្រោះជាបុរសចំនួន ១១៤ នាក់ពីប្រទេស Mauritius ឥណ្ឌូនេស៊ី សេណេហ្គាល់ ម៉ាឡេស៊ី

និងអាហ្វ្រិកខាងត្បូង នៅក្នុងឆ្នាំ ២០១៣ ដែលជាចំនួនច្រើនជាង ២ ដងនៃចំនួនដែលបានជួយនៅក្នុងឆ្នាំ ២០១២។ រដ្ឋាភិបាលគ្មាននិតិវិធីគ្រប់គ្រាន់សំរាប់សំរួលដល់ការជួយសង្គ្រោះ និងនាំត្រឡប់វិញនូវជនរងគ្រោះពីការចាប់បង្ខំអោយធ្វើការនៅតាមទូកនេសាទ ដែលត្រូវបានគេរកឃើញនៅបរទេសឡើយ។ កង្វះតំណាងផ្នែកទូត ឬកិច្ចព្រមព្រៀងទ្វេភាគីដទៃទៀតនៅក្នុងប្រទេសខ្លះដែលជនរងគ្រោះត្រូវបានរកឃើញ ធ្វើអោយជនរងគ្រោះមិនសូវមានសង្ឃឹមក្នុងការទទួលបានការជួយ។ នៅក្នុងអំឡុងឆ្នាំនៃរបាយការណ៍ឆ្នាំនេះ រដ្ឋាភិបាលបានហាមប្រាមមិនអោយនារីធ្វើចំណាកស្រុកទៅប្រទេសម៉ាឡេស៊ីដើម្បីបំរើការងារតាមផ្ទះ តែមិនបានធានាថា មាននិតិវិធី ឬបញ្ញត្តិការពារសំរាប់ជួយនារីខ្មែរដែលកំពុងតែធ្វើការនៅប្រទេសម៉ាឡេស៊ីទេ។ រដ្ឋាភិបាលបាននិយាយថា បានដាក់អនុព័ន្ធការងារប្រចាំនៅតាមស្ថានទូតរបស់ខ្លួននៅប្រទេសកូរេ ថៃ និងម៉ាឡេស៊ី។ ស្ថានទូតកម្ពុជានៅទីក្រុងគូឡាឡាំពួបានផ្តល់ទីជំរកបណ្តោះអាសន្នដល់ជនជាតិខ្មែរខ្លះដែលបំរើការងារតាមផ្ទះ ដែលប្រឈមនឹងការធ្វើបាបនៅប្រទេសម៉ាឡេស៊ី ហើយបានជួយអង្គការមិនមែនរដ្ឋាភិបាលក្នុងការបញ្ជូនមកមាតុភូមិវិញនូវពលករចំណាកស្រុកខ្មែរចំនួន ៣០ នាក់ តែស្ថានទូតគ្មាននិតិវិធីជាប្រព័ន្ធសំរាប់ជួយជនរងគ្រោះដោយការជួញដូរ តាមរយៈបេសកកម្មទូតរបស់ខ្លួននៅប្រទេសម៉ាឡេស៊ី ឬនៅប្រទេសដទៃទេ។

ភាគច្រើននៃសេវាផ្នែកវិជ្ជាជីវៈ ទីជំរក ច្បាប់ និងសេវាសុខភាពសំរាប់ជនរងគ្រោះដោយសារការជួញដូរទាំងក្នុងស្រុក និងនៅបរទេសត្រូវបានផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល ដែលភាគច្រើនយកចិត្តទុកដាក់ចំពោះជនរងគ្រោះដោយការធ្វើបាបក្នុងទំរង់មួយចំនួន។ ក្នុងឆ្នាំនៃរបាយការណ៍នេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងស្តារយុវនិតិសម្បទាបានសំរេចលើគោលការណ៍ណែនាំសំរាប់ជាបទដ្ឋាននៃការថែទាំ នៅតាមកន្លែងស្នាក់នៅសំរាប់ជនរងគ្រោះដោយការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទនៅកម្ពុជា។ យ៉ាងណាក្តី នៅមានការចោទប្រកាន់ថា កន្លែងជំរករបស់អង្គការមិនមែនរដ្ឋាភិបាលខ្លះធ្វើអោយជនរងគ្រោះរងការធ្វើបាប ឬការថែទាំមិនបានគ្រប់គ្រាន់ និងថាការមើលមិនគ្រប់គ្រាន់របស់រដ្ឋាភិបាលបានបណ្តាលអោយទង្វើបែបនេះកើតឡើងដោយមាននិទណ្ឌភាព។ជាធម្មតា អាជ្ញាធរបញ្ជូនជនរងគ្រោះដែលត្រូវបានរកឃើញ ទៅអោយអង្គការមិនមែនរដ្ឋាភិបាលអោយទទួលថែទាំ តែគ្មានគោលនយោបាយសំរាប់ផ្ទេរការគ្រប់គ្រងជនរងគ្រោះជាកុមារទេ ដែលជាការធ្វើអោយអង្គការដែលបានទទួលថែទាំជនរងគ្រោះទាំងនោះ ប្រឈមនឹងបណ្តឹងតុលាការប្រឆាំងនឹងពួកគេ។ កង្វះការថែទាំរយៈពេលយូរដោយរួមទាំងសេវាសុខភាពខួរក្បាលផង បានធ្វើអោយជនរងគ្រោះ ពិសេស ជនរងគ្រោះដោយការជួញដូរផ្លូវភេទជាកុមារ ងាយទទួលរងការជួញដូរជាថ្មី។ ទោះបីជាមានជនរងគ្រោះជាបុរសច្រើនក្តី តែជំនួយសំរាប់ក្រុមនេះមានបើសិនជាមាន គឺមានត្រឹមការផ្តល់កន្លែងជំរកបណ្តោះអាសន្ននៅតាមកន្លែងដែលខ្វះបទពិសោធន៍ក្នុងការថែទាំជន

រងគ្រោះដោយការជួញដូរ។ កន្លែងជំរកសំរាប់ទទួលជនរងគ្រោះដោយការជួញដូរមិនព្រមទទួលយកបុរស ហើយរដ្ឋាភិបាលមិនបានផ្តល់កន្លែង ឬសេវាផ្សេងក្រៅពីបញ្ជូនជនរងគ្រោះជាបុរសទេ។ ជនរងគ្រោះដោយការជួញដូរជាជនបរទេសអាចទៅរកកន្លែងថែទាំសំរាប់ជនរងគ្រោះបានដូចជនរងគ្រោះដោយការជួញដូរជាជនជាតិខ្មែរដែរ។ ប៉ុន្តែ ចំនួននៃកន្លែងជំរកដែលអាចផ្តល់ការថែទាំពិសេសសំរាប់ជនរងគ្រោះជាជនបរទេស គឺមានមិនច្រើនទេ ដែលក្នុងនោះរួមមានកន្លែងដែលមានសមត្ថភាពផ្នែកភាសាបរទេស និងការជួយសមទៅតាមវប្បធម៌ប្រពៃណីរបស់គេ។

រដ្ឋាភិបាលកម្ពុជាតំរូវអោយជនរងគ្រោះជាជនបរទេសដែលត្រូវបានរកឃើញនៅកម្ពុជាត្រូវនាំទៅមាតុភូមិគេវិញ ហើយមិនបានផ្តល់ជំរើសផ្លូវច្បាប់ផ្សេងក្រៅពីការបញ្ជូនគេទេ ក្នុងករណីដែលគេជួបប្រទះការលំបាក ឬការធ្វើបាបនៅពេលទៅដល់ប្រទេសកំណើតរបស់គេវិញ។ គ្មានសេចក្តីរាយការណ៍ថា ជនរងគ្រោះបានទទួលទណ្ឌកម្មចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តជាលទ្ធផលនៃការត្រូវបានគេជួញដូរទេ តែជនរងគ្រោះដោយការជួញដូរជាច្រើនមិនត្រូវបានគេកំណត់ជាផ្លូវការទេ ហើយជនរងគ្រោះដែលមិនត្រូវបានគេកំណត់បានអាចប្រឈមនឹងការដាក់ទណ្ឌកម្ម។ អាជ្ញាធរ តាមសេចក្តីរាយការណ៍មក បានលើកទឹកចិត្តអោយជនរងគ្រោះចូលរួមក្នុងការស៊ើបអង្កេត និងការនាំជនប្រព្រឹត្តការជួញដូរមកកាត់ទោស ហើយជនរងគ្រោះជាជនបរទេស អាចស្នាក់នៅបណ្តោះអាសន្ន ដើម្បីចូលរួមក្នុងការស៊ើបអង្កេត និងការកាត់ទោស។ យ៉ាងណាក្តី ប្រព័ន្ធអនុវត្តច្បាប់ និងប្រព័ន្ធតុលាការទន់ខ្សោយ និងប្រកបដោយអំពើពុករលួយរបស់ប្រទេសកម្ពុជានិងកង្វះការការពារដល់ជនរងគ្រោះ ធ្វើអោយជនរងគ្រោះមិនចង់ធ្វើសហប្រតិបត្តិការនៅក្នុងករណីនានា និងជាឧបសគ្គដល់លទ្ធភាពរបស់គេក្នុងការទទួលបានយុត្តិធម៌តាមផ្លូវច្បាប់។ ថ្វីបើរដ្ឋាភិបាលបានតំរូវអោយអ្នកផ្តល់សេវា និងនគរបាលធ្វើការសំភាសន៍ជាមួយជនរងគ្រោះនៅកន្លែងសុវត្ថិភាពក្តី តែជាធម្មតា រដ្ឋាភិបាលខ្វះបរិក្ខា និងកន្លែងការិយាល័យចាំបាច់សំរាប់ធ្វើការសំភាសន៍ជនរងគ្រោះក្នុងលក្ខណៈបែបនេះ ហើយជាញឹកញាប់ ជនរងគ្រោះ និងជនល្មើសត្រូវបានសំភាសន៍នៅកន្លែងតែមួយ។ ជាគោលការណ៍ ជនរងគ្រោះអាចទទួលសំណង តែជាក់ស្តែង ករណីសងនេះមិនសូវមានធ្វើច្រើនទេ ដោយសារច្បាប់តំរូវអោយទូទាត់សងតែនៅពេលជនល្មើសចេញពីពន្ធនាគារវិញតែប៉ុណ្ណោះ បន្ទាប់ពីបំពេញទោសហើយ។

**ការបង្ការ ( Prevention )**

រដ្ឋាភិបាលកម្ពុជាបានបន្តការខិតខំមិនសូវជាច្រើនទេក្នុងការការពារកុំអោយមានការជួញដូរមនុស្ស។ គណកម្មាធិការជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ការរត់ពន្ធ និងការកេងប្រវ័ញ្ចផ្លូវភេទ និងកំលាំង

ពលកម្ម និងលេខាធិការដ្ឋានរបស់គណកម្មាធិការនេះ (គណកម្មាធិការជាតិ) បានបន្តដឹកនាំការខិតខំប្រឆាំងការជួញដូររបស់ប្រទេសកម្ពុជា ហើយអនុវត្តផែនការសកម្មភាពប្រឆាំងការជួញដូររបស់គណកម្មាធិការ តែគេបាននិយាយពីការគ្មានថវិកាគ្រប់គ្រាន់ ដើម្បីអនុវត្តផែនការអោយមានប្រសិទ្ធភាព។ រដ្ឋាភិបាលបានបន្តចរចាលើអនុស្សារណៈយោគយល់គ្នាទ្វេភាគីជាមួយរដ្ឋាភិបាលម៉ាឡេស៊ី ស្តីពីការធ្វើចំណាកស្រុករបស់ជនជាតិខ្មែរទៅរកការងារធ្វើតាមផ្ទះនៅប្រទេសម៉ាឡេស៊ី តែក្នុងឆ្នាំនៃរបាយការណ៍នេះ គេមិនទាន់ឈានដល់កិច្ចព្រមព្រៀងចុងក្រោយទេ។ ការខិតខំរបស់រដ្ឋាភិបាលក្នុងការដាក់ទណ្ឌកម្មលើអ្នកជ្រើសរើសពលករខិលខូចមានការថយចុះ។ បន្ទាប់ពីបានដាក់ទោសលើបុគ្គលិក ៤ រូបនៃទីភ្នាក់ងារជ្រើសរើសពលករមួយដែលមានអាជ្ញាប័ណ្ណ ទាក់ទងនឹងការជួញដូរពលកម្ម ក្នុងអំឡុងពេលនៃរបាយការណ៍លើកមុន រដ្ឋាភិបាលបានធ្វើការចាប់ខ្លួនតែម្នាក់ទេ ហើយមិនបានធ្វើការដាក់ទណ្ឌកម្មចំពោះការជ្រើសរើសពលករដោយខុសច្បាប់នៅក្នុងឆ្នាំនេះទេ។ អ្នកសង្កេតការណ៍ក្នុងស្រុកជឿថា អំពើពុករលួយគឺជាបុព្វហេតុនៃការផ្តល់និទណ្ឌភាពដល់ក្រុមហ៊ុនជ្រើសរើសពលករដែលធ្វើការជ្រើសរើសពលករក្នុងលក្ខណៈដែលជួយនាំអោយមានការជួញដូរមនុស្ស ដោយមានក្រុមហ៊ុនខ្លះត្រូវបានរាយការណ៍មកថាមានចំណែកភាគហ៊ុនជាមួយមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល។

ដោយមានការជួយពីម្ចាស់អំណោយបរទេស និងម្ចាស់អំណោយក្នុងស្រុក រដ្ឋាភិបាលបានបន្តផលិត និងផ្សព្វផ្សាយឯកសារបោះពុម្ព ធ្វើការផ្សាយតាមវិទ្យុ និងការតាំងបង្ហាញតាមផ្ទាំងប៉ាណូ និងផ្ទាំងរូបទាក់ទងនឹងគ្រោះថ្នាក់នៃការជួញដូរមនុស្សដែលមានទំរង់ផ្សេងៗ។ ពេលខ្លះ រដ្ឋាភិបាលប្រហែលជាបានធ្វើអោយរាំងស្ទះដល់ការងាររបស់សង្គមស៊ីវិលដោយតំរូវអោយមានការយល់ព្រមពីរដ្ឋាភិបាលជាមុនសិនទៅលើឯកសារដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាល នៅមុនពេលយកទៅផ្សព្វផ្សាយជាសាធារណៈ។ ក្រសួងទេសចរណ៍បានរក្សាការសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងការធ្វើការបណ្តុះបណ្តាល ធ្វើផ្ទាំងប៉ាណូ និងក្រដាសចែកចាយ ដែលមានបំណងកាត់បន្ថយតំរូវការលើជំនួញផ្លូវភេទ និងទេសចរណ៍ផ្លូវភេទលើកុមារ ថ្វីបើការខិតខំទាំងនេះសំដៅលើទេសចរផ្លូវភេទបរទេស ជាជាងមនុស្សនៅក្នុងប្រទេស ដែលជាប្រភពធំនៃតំរូវការលើជំនួញផ្លូវភេទលើកុមារក្តី។ អាជ្ញាធរបាននិយាយថា បានចាប់ខ្លួនជនបរទេសចំនួន ៩ នាក់ ហើយបានដាក់ទោសលើពួកគេចំនួន ៣ នាក់ពីបទធ្វើទេសចរណ៍ផ្លូវភេទលើកុមារ។ យ៉ាងណាក្តី អ្នកសង្កេតការក្នុងស្រុកបាននិយាយថា នៅមានកង្វល់ជាបន្តលើការខកខានរបស់រដ្ឋាភិបាលក្នុងការធ្វើការស៊ើបអង្កេតអោយបានត្រឹមត្រូវ ឬដាក់ទោសទៅលើជនបរទេសដែលបានប្រើលុយដើម្បីទិញកុមារមករួមភេទជាមួយ។ អាជ្ញាធរបាននិយាយថា បានដាក់ទោសលើពលរដ្ឋខ្មែរចំនួន ៤ នាក់ពីបទប្រើលុយដើម្បីទិញកុមារមករួមភេទជាមួយ។ រដ្ឋាភិបាលបាននិយាយថា កម្មវិធីបណ្តុះបណ្តាលរបស់ខ្លួន

ដល់អ្នកការទូត មុនពេលពួកគេចេញទៅបំពេញការងារនៅបរទេស រួមមានការបង្រៀនពីគោលនយោបាយប្រឆាំងការជួញដូររបស់ប្រទេសកម្ពុជា។ គណកម្មាធិការជាតិបានបង្រៀនដល់កងកំលាំងប្រដាប់អាវុធស្តីពីការជួញដូរមនុស្ស មុនពេលបញ្ជូនពួកគេអោយទៅបំពេញបេសកកម្មថែរក្សាសន្តិភាពនៅបរទេស។